## ខេត្តក្រចេះ

## សក្តានុពលវិនិយោគ

សីហា ឆ្នាំ ២០០៨




# ខេត្តក្រចេះ

## ច្រកចូលទៅកាន់ប៉ែកឦសាននៃព្រះរាជាណាចក្រកម្ពុជា









USAID
ជំនួយពីពលរដ្ឋអាមេរិក

**បញ្ជាក់:**
ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកនោះទេ។



## របាយការណ៍វិនិយោគខេត្តក្រចេះ


**បតិសូាគមន៍ពីឯកឧត្តមអភិបាលខេត្ត** ........ ២

**ចំណុចខ្លាំងរបស់ប្រទេស** ........ ៣

បរិយាកាសអាជីវកម្មបើកចំហ
កំលាំងពលកម្មដែលមានតម្លៃឈ្នួលពលកម្មទាប
ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

**តើហេតុអ្វីជ្រើសរើសយកខេត្តក្រចេះ?** ........ ៤

១. ទីតាំង – នៅជិតក្រុងភ្នំពេញ និងវៀតណាម
២. ច្រកទ្វារទៅកាន់ភាគឦសាន – "ប៉ូលសេដ្ឋកិច្ចបន្ទាប់" របស់កម្ពុជា
៣. វិស័យទេសចរណ៍មានភាពរីកចំរើនជឿនលឿន
៤. ការផ្គត់ផ្គង់អគ្គិសនីច្រើន
៥. ធនធានធម្មជាតិដែលមិនទាន់បានទាញយកមកប្រើ

**ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត** ........ ៥

**ឱកាសធ្វើអាជីវកម្ម** ........ ៧

**ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ** ........ ៧

**ត្រូវការស្វែងយល់បន្ថែមទៀតទេ?** ........ ៨



របាយការណ៍វិនិយោគនេះផលិតដោយ EMC សំរាប់គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម នៅកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។








# មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត

ខេត្តក្រចេះជាផ្លូវចូលទៅកាន់ភូមិភាគឦសានដ៏ស្រស់ត្រកាលនៃប្រទេសកម្ពុជា។ ដោយខេត្តក្រចេះដើរតួនាទីជាចំណតកំពង់ផែផងនោះ ខេត្តនេះបើកទូលាយដល់ការធ្វើដំណើរកំសាន្តតាមបែបធម្មជាតិប្រចាំតំបន់តាមដងទន្លេមេគង្គ ជួរភ្នំប្រវត្តិសាស្ត្រ ទឹកជ្រោះដ៏គួរឱ្យគយគន់ ព្រៃភ្នំតូចធំ ជីវិតសត្វព្រៃយ៉ាងសម្បូរបែប ព្រមទាំងក្រុមកុលសម្ព័ន្ធជនជាតិភ្នំភាគតិចដ៏គួរឱ្យចាប់អារម្មណ៍ជាច្រើនទៀត ។

ក្រៅពីភាពល្បីសុះសាយផ្នែកមរតកវប្បធម៌និងធនធានធម្មជាតិរបស់ខ្លួន ខេត្តក្រចេះថែមទាំងជាទីអាស្រ័យនៅរបស់ពពួកហ្វូងសត្វផ្សោតដ៏ល្បីល្បាញ។ ថនិកសត្វដ៏កម្រទាំងនេះជាវត្ថុដ៏សំខាន់ប្រចាំខេត្តនេះ ។

យើងមិនមែនគ្រាន់តែជាផ្លូវចេញចូលសំរាប់ការធ្វើដំណើរសាមញ្ញប៉ុណ្ណោះទេ ខេត្តក្រចេះកំពុងតែទទួលបាននូវភាពរីកចំរើនផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងប្រកបដោយចេរភាព។ បើទោះជាយើងនៅតែមានតួនាទីផ្តល់ផ្លូវចូល សំរាប់ការធ្វើដំណើរតាមបែបធម្មជាតិយ៉ាងណាក្តី ក៏វាមិនមានន័យថា យើងអាចផ្តល់អ្វីៗគ្រប់យ៉ាងនោះដែរ ។ ហេដ្ឋារចនាសម្ព័ន្ធផ្នែកអាជីវកម្មរបស់យើងល្អឥតខ្ចោះ ។ ផ្លូវថ្នល់ថ្មីៗបានកាត់បន្ថយពេលវេលាធ្វើដំណើរ ព្រមទាំងជំរុញឱ្យមានការធ្វើអាជីវកម្មថ្មីៗផងដែរ ។ យើងមានព្រំប្រទល់ជាប់ប្រទេសវៀតណាម ដែលផ្តល់នូវឱកាសក្នុងការធ្វើពាណិជ្ជកម្មដ៏គួរឱ្យចាប់អារម្មណ៍ ព្រមទាំងផ្តល់ឱ្យយើងនូវប្រភពថាមពលវារីអគ្គិសនីថែមទៀត ។

ដើម្បីបន្តលើកកំពស់មូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេសយើង និងបន្តពង្រឹងកិត្តិស័ព្ទរបស់យើងជាតំបន់អនុគ្រោះដល់ផ្នែកវិនិយោគទុនប្រចាំប្រទេសកម្ពុជានោះ អាជ្ញាធរខេត្តក្រចេះបានបំពេញការងាររបស់ខ្លួន ដើម្បីពង្រឹងបរិយាកាសអាជីវកម្មបន្ថែមទៀត ។

ទោះជាយ៉ាងណាក៏ដោយ ក៏យើងមិនបញ្ឈប់ត្រឹមនេះដែរ យើងនៅតែបន្តកែលំអខេត្តរបស់យើងឱ្យកាន់តែមានការទាក់ទាញវិនិយោគទុនបន្ថែមទៀត ព្រមទាំងថែរក្សាសហគ្រាសអាជីវកម្មដែលមានស្រាប់ឱ្យបានគង់វង្សទៀតផង។ យើងរីករាយចំពោះសក្តានុពលភាពក្នុងការពង្រឹង និងពង្រីកមូលដ្ឋានឧស្សាហកម្មរបស់យើង ព្រមទាំងបើកចំហទទួលស្វាគមន៍វិនិយោគិនទាំងក្នុង និងក្រៅប្រទេសថែមទៀត ។ យើងនឹងព្យាយាមឱ្យអស់ពីលទ្ធភាព ដើម្បីបង្កលក្ខណៈងាយស្រួល និងធ្វើឱ្យអ្នកចំណាយធនធានតិចក្នុងការបង្កើត និងការប្រកបមុខជំនួញរបស់ខ្លួន ហើយយើងនឹងប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ដើម្បីផ្តល់បរិយាកាសជំនួញប្រកបដោយស្ថេរភាព និងអាចទុកចិត្តបាន ។

ខ្ញុំសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដែលបានជួយឧបត្ថម្ភក្នុងការរៀបចំបង្កើតរបាយការណ៍វិនិយោគ និងបានបន្តគាំទ្រលើការផ្សព្វផ្សាយការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តរបស់យើងខ្ញុំ។

ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយវិនិយោគិនទាំងអស់ ដើម្បីជួយធ្វើឱ្យអាជីវកម្មរបស់ពួកគេ ព្រមទាំងខេត្តដែលមានសក្តានុពលរបស់យើងនេះកាន់តែមានភាពរីកចំរើនឡើងថែមទៀត។

សូមទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ឯកឧត្តម ខាំ ភឿន**
អភិបាលខេត្តក្រចេះ





## ចំណុចខ្លាំងរបស់ប្រទេស

សំរាប់រយៈពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានចេញមុខជាអ្នកប្រកួតប្រជែងក្នុងតំបន់ដ៏រឹងមាំ និងរហ័សរហួនដោយមានភោគទ្រព្យយ៉ាងសម្បូរបែបដែលមានសារៈសំខាន់បំផុតសំរាប់កំណើន និងការអភិវឌ្ឍន៍អាជីវកម្មប្រកបដោយជោគជ័យ ។

**បើកទូលាយសំរាប់អាជីវកម្ម**

- ពន្ធលើប្រាក់ចំណេញដែលមានតម្លៃទាប - ពន្ធ ២០% លើប្រាក់ចំណេញ ( ការខាតបង់ ៥ ឆ្នាំទៅមុខ)
- ពុំមានការកំណត់លក្ខខណ្ឌកាន់កាប់បរទេសទេ ។ ប្រទេសកម្ពុជាអនុញ្ញាតឱ្យមានសម្ព័ន្ធអាជីវកម្មរួមគ្នា ឬក្រុមហ៊ុនដែលកាន់កាប់ដោយបរទេសប្រតិបត្តិការ ១០០% ដោយមានសិទ្ធិពេញលេញដែលអាចនាំចូល និងនាំចេញផលិតផលបានស្ទើរគ្រប់ប្រភេទ ។
- វិនិយោគិនទាំងអស់ទទួលបានការការពារប្រកបដោយសមភាព ។
- ប្រទេសកម្ពុជាមានសេរីភាពសេដ្ឋកិច្ចជាង ចិន ឥណ្ឌា វៀតណាម និងឥណ្ឌូនេស៊ី[1] ។
- ពុំមានការគ្រប់គ្រងតម្លៃផលិតផល ឬសេវាណាមួយទេ ។
- ពុំមានការគ្រប់គ្រងការប្តូររូបិយប័ណ្ណបរទេស ឬការកំណត់លក្ខខណ្ឌទៅលើការប្តូររូបិយប័ណ្ណនេះទេ ។
- ពុំមានការកំណត់លក្ខខណ្ឌស្តីពីការបង្វិលទុនទេ ។
- សមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន ។
- ពុំមានការកំណត់លក្ខខណ្ឌពាណិជ្ជកម្មបរិមាណ និងមានការទំលាក់ថ្លៃរបាំងពន្ធគយទេ ។ ប្រទេសកម្ពុជាអាចទទួលបានការលើកលែងពន្ធនិងការកំណត់កូតានៅលើទីផ្សារពិភពលោកធំៗ ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ជប៉ុន និងបណ្តាប្រទេសសមាជិកអាស៊ានជាច្រើនទៀត ។
- អជ្ញាធរខេត្តមានសិទ្ធិអនុម័តការវិនិយោគទុនក្រោម ២ លានដុល្លារ ដើម្បីការចាប់ផ្តើមអភិវឌ្ឍន៍អាជីវកម្មឆាប់រហ័ស ។

*"ប្រទេសកម្ពុជា បើកទូលាយយ៉ាងពេញលេញសំរាប់អាជីវកម្ម ហើយរាជរដ្ឋាភិបាលកម្ពុជា នឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីធានានូវបរិយាកាសគួរជាទីពេញចិត្ត និងជោគជ័យដល់គ្រប់សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។"*

- សម្តេច អគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

### កំលាំងពលកម្មដែលមានតម្លៃទាប

បើប្រៀបធៀបទៅនឹងដៃគូប្រកួតប្រជែងក្នុងតំបន់ជាច្រើន ប្រទេសកម្ពុជារីករាយនឹងទទួលយកអត្រាប្រាក់ឈ្នួលទាបសមរម្យក្នុងគោលដៅទាក់ទាញឧស្សាហកម្មដែលប្រើកំលាំងពលកម្មច្រើន ។

ឆ្លងកាត់រយៈកាលជាច្រើនឆ្នាំចុងក្រោយនេះ កំលាំងពលកម្មនៅប្រទេសកម្ពុជាបានកើនឡើងជាង ៥០% ដែលច្រើនជាងពីរដងនៃអត្រានៅក្នុងប្រទេសសមាជិកអាស៊ានផ្សេងទៀត ។

ហើយដោយសារមានប្រជាជនវ័យក្មេងចំនួនច្រើន (ចំនួនពាក់កណ្តាលមានអាយុក្រោម ២០ឆ្នាំ ) ទើបធ្វើឱ្យកំណើននៃកំលាំងពលកម្មនេះ នឹងបន្តកើនឡើង ។

1.The Heritage Foundation *លិបិក្រមនៃសេរីភាពសេដ្ឋកិច្ច ឆ្នាំ២០០៨ ។*
http://www.heritage.org/index/

### ប្រាក់ឈ្នួលក្នុងឧស្សាហកម្មកាត់ដេរ [2]

| ប្រទេស | អត្រាប្រាក់ឈ្នួលក្នុងមួយម៉ោង (US$) |
|---|---|
| កម្ពុជា | 0.33 |
| ចិន | 0.88[a]/0.66[b] |
| ប៉ាគីស្ថាន | 0.41 |
| ឥណ្ឌា | 0.38 |
| ឥណ្ឌូនេស៊ី | 0.30 |
| បង់ក្លាដេស | 0.39 |

ការចំណាយទៅលើការអប់រំនៅបឋមសិក្សា ដែលជាចំណែកផលិតផលសរុបក្នុងស្រុកមានការកើនឡើងគួរឱ្យកត់សំគាល់នៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយបច្ចុប្បន្ននេះកំពុងតែស្មើគ្នាជាមួយនឹងថៃ ។ រដ្ឋាភិបាលមានផែនការបន្តបង្កើនការចំណាយទៅលើផ្នែកអប់រំបន្ថែមទៀត ។

### ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅចំកណ្តាលតំបន់ដែលមានសក្តានុពលបំផុតនៅលើពិភពលោក ។ ស្ថិតនៅប៉ែកកណ្តាលនៃប្រទេសថៃ និងប្រទេសវៀតណាម ប្រទេសកម្ពុជាគឺជាផ្នែកមួយនៃច្រកសេដ្ឋកិច្ចខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ ដែលលាតសន្ធឹងចេញពីទីក្រុង ហូជីមីញរហូតដល់ទីក្រុងបាងកក ។

ដោយសារទីតាំងយុទ្ធសាស្ត្ររបស់ខ្លួន ប្រទេសកម្ពុជារីករាយនឹងទទួលយកការគាំទ្រពីសំណាក់អន្តរជាតិដ៏សំខាន់ៗ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួន ដើម្បីសម្រួលដល់អាជីវកម្មក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផលពាណិជ្ជកម្មជាមួយនឹងប្រទេសវៀតណាម និងប្រទេសថៃកំពុងតែរីកចម្រើនឡើងយ៉ាងឆាប់រហ័ស ។




2. *ចំណាំ:* a) *តំបន់ឆ្នេរ* b) *តំបន់ដីគោក*
*ប្រភព: បាហ្គាវី (Bargawi) "ឧស្សាហកម្មកាត់ដេរកម្ពុជា -ប្រភព និងការរំពឹងទុកពេលអនាគត" វិទ្យាស្ថានអភិវឌ្ឍន៍ការគ្រប់គ្រង ឆ្នាំ ២០០៥ ។*





*"មានទីក្រុងធំជាងគេចំនួនពីរនៅក្នុងអាស៊ីនៅអមសងខាងប្រទេសរបស់អ្នក ។ ប្រជាជនចំនួន១៥លាននាក់នៅទីក្រុងបាងកក និង៨លាននាក់នៅទីក្រុងហូជីមិញ ហើយកំណើនផ្សេងៗ មានការកើនឡើងជាលំដាប់នៅកណ្តាលនៃទីក្រុងទាំងពីរ ។"*

- Edward Hopkins, CB Richard Ellis Group Inc.

# តើហេតុអ្វីជ្រើសរើសយកខេត្តក្រចេះ?

## ១. ទីតាំង – នៅជិតក្រុងភ្នំពេញ និងវៀតណាម

ខេត្តក្រចេះ ចំណាយពេលបើកបរត្រឹមតែ ៤ ម៉ោងប៉ុណ្ណោះពីក្រុងភ្នំពេញ ដែលជាទីផ្សារធំជាងគេបំផុតនៅក្នុងប្រទេស ហើយចំណាយពេលធ្វើដំណើរត្រឹមតែ ១ ម៉ោងកន្លះប៉ុណ្ណោះពីប្រទេសវៀតណាម ។

ការមានព្រំដែននៅកៀកគ្នា និងជាប់គ្នាជាមួយនឹងប្រទេសវៀតណាមបានផ្តល់នូវឱកាសដ៏មានប្រសិទ្ធិភាពក្នុងការចូលមកកាន់ទីផ្សារដ៏ធំមួយ សំរាប់ផលិតកម្មកសិកម្មរបស់ខេត្តនេះ ។ ការធ្វើពាណិជ្ជកម្មឆ្លងដែនតាមទិសដៅទាំងពីរមានលក្ខណៈសកម្ម និងកំពុងតែមានការរីកចំរើន ។

**កម្ពុជា_ខេត្តក្រចេះ រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរួមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោង
រយៈពេលធ្វើដំណើរទៅកាន់ទីក្រុង បាងកក និង ហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែនទេ ។

ខេត្តនេះមានរចនាសម្ព័ន្ធផ្លូវថ្នល់ដឹកជញ្ជូនដ៏ប្រសើរ ដែលបម្រើឱ្យការដឹកជញ្ជូនតាមមធ្យោបាយផ្សេងៗ ពីតំបន់មួយទៅកាន់តំបន់មួយទៀតនៃប្រទេសកម្ពុជា ។

### បណ្តាញផ្លូវគោក

ខេត្តក្រចេះមានផ្លូវជាតិចំនួនបួនខ្សែ មានចម្ងាយ ៣០០គម ដែលគ្របដណ្តប់ទូទាំងខេត្ត ហើយបម្រើដល់អ្នកប្រើប្រាស់ និងការធ្វើអាជីវកម្មនៅទូទាំងប្រទេស ។

ផ្លូវថ្នល់របស់យើងមានលក្ខណៈល្អប្រសើរ ហើយអនុញ្ញាតឱ្យមានការធ្វើដំណើរចេញចូលបានយ៉ាងឆាប់រហ័សពីក្រុងភ្នំពេញ និងវៀតណាមទៅកាន់ខេត្តក្រចេះ និងបន្តទៅខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគីរី ។ ជាលទ្ធផល យើងមានអាជីវកម្មជាច្រើនដែលកំពុងតែមានការកើនឡើងនៅក្នុងខេត្តក្រចេះយើងនេះ ។

ផ្លូវជាតិលេខ ៧៣ ដែលបានពង្រីក និងចាក់ក្រាលកៅស៊ូថ្មីៗនេះ កាត់បន្ថយចម្ងាយបើកបរពីក្រុងភ្នំពេញបាន ៨០គម ដែលបានជួយកាត់បន្ថយរយៈពេលធ្វើដំណើរយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

លើសពីនេះទៅទៀត ផ្លូវជាតិលេខ ៧ ត្រូវបានសាងសង់រួចជាស្ថាពរកាលពីខែមេសាឆ្នាំ២០០៨នេះ ។ ផ្លូវនេះលាតសន្ធឹងចេញពីខេត្តក្រចេះទៅកាន់ខេត្តកំពង់ចាម ។ បរិមាណចរាចរណ៍ផ្លូវគោកមានការកើនឡើងជាង ៣៥០% តាំងពីឆ្នាំ១៩៩៧មក ។ ផ្លូវនេះគឺជាផ្នែកមួយនៃបណ្តាញផ្លូវអាស៊ានស្នូល ហើយក៏ភ្ជាប់ទឹកដីឡាវទៅកាន់កំពង់ផែក្រុងព្រះសីហនុផងដែរ ។ ផ្លូវនេះនឹងបម្រើដល់អាជីវកម្មរបស់ខេត្តក្រចេះជាមួយនឹងទីផ្សារស្នូលនានាបានយ៉ាងយូរអង្វែង ។

### បណ្តាញផ្លូវទឹក

ខេត្តក្រចេះមានទីតាំងនៅតាមបណ្តោយទន្លេមេគង្គ ដែលហូរពីប្រទេសឡាវឆ្លងកាត់ភាគឦសាននៃប្រទេសកម្ពុជា ហើយចូលទៅក្នុងប្រទេសវៀតណាម ។ កំពង់ផែមានចម្ងាយខ្សែទឹកខាងលើ ២២០គម ពីក្រុងភ្នំពេញ ។ ដោយសារទន្លេនេះមានលក្ខណៈល្អប្រសើរសំរាប់ការធ្វើដំនើរ និងការដឹកជញ្ជូនផលិតផលក្នុងស្រុកចំនួនដ៏ច្រើន ទន្លេនេះគឺជាសមាសភាគមួយដ៏សំខាន់នៃអត្តសញ្ញាណ និងបណ្តាញដឹកជញ្ជូនរបស់ខេត្តនេះ តាំងពីយូរយារណាស់មកហើយ ។

### បណ្តាញផ្លូវដែក

រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមកសាងបណ្តាញផ្លូវដែកមួយខ្សែចេញពីខេត្តកណ្តាល ឆ្លងកាត់ស្រុកស្នួលរបស់ខេត្តក្រចេះទៅកាន់ខេត្តឡុកនិញរបស់ប្រទេសវៀតណាម ។ ផ្លូវដែកនេះនឹងជួយកែលំអដល់ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មរវាងខេត្តក្រចេះ និងប្រទេសវៀតណាម ។

## ២. ច្រកទ្វារទៅកាន់ភាគឦសាន – "ប៉ូលសេដ្ឋកិច្ចបន្ទាប់" របស់កម្ពុជា

ដោយមានទីតាំងនៅតាមបណ្តោយទន្លេមេគង្គ ខេត្តក្រចេះគឺជាច្រកទ្វារចូលទៅកាន់ភូមិភាគឦសានដ៏ស្រស់ស្អាតរបស់កម្ពុជា ដែលជាតំបន់ភ្នំ ព្រៃឈើ បឹង ឧទ្យានសត្វព្រៃ និងកុលសម្ព័ន្ធភ្នំជនជាតិភាគតិច ។

ទឹកដីប្រទេសកម្ពុជាមួយភាគនេះភ្ជាប់ព្រំដែនគ្នារវាងប្រទេសវៀតណាម និងប្រទេសឡាវ ។ ភូមិភាគនេះមានចំនួនប្រជាជនជិត ៦០០ ០០០ នាក់ ដែលប្រជាជនភាគច្រើនរស់នៅជិតផ្លូវទឹកសំខាន់ៗ ។

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ជ្រើសរើសយកភូមិភាគនេះជា "ប៉ូលសេដ្ឋកិច្ចទីបួនរបស់កម្ពុជា" (បន្ទាប់ពីក្រុងភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ) ដោយសារតែសក្តានុពលធនធានធម្មជាតិ និងទេសចរណ៍ធម្មជាតិដ៏ធំធេងរបស់ខេត្តនេះ[3] ។

---

[3] *សន្ទរកថារបស់សម្តេចអគ្គសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៨ ដែលបានរាយការណ៍ពីកាសែត ដឹ មេគង្គថៃមស៍ ចេញផ្សាយលេខ ៥៧ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ ។*





ដោយមានទីតាំងភូមិសាស្ត្រដ៏ល្អប្រសើរបែបនេះ ខេត្តក្រចេះគឺជាចំណុចកណ្តាលនៃអាជីវកម្ម និងទេសចរណ៍សំរាប់ភូមិភាគឦសានរបស់កម្ពុជា និងសំរាប់ការធ្វើដំណើរចេញចូលប្រទេសឡាវ ។

ខេត្តក្រចេះ ក៏ជាខេត្តមួយដែលផ្គត់ផ្គង់ទំនិញទៅឱ្យផលិតកម្មកសិកម្ម នៃបណ្តាខេត្តនានានៅភូមិភាគឦសានផងដែរ ដូចជាខេត្តស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី ។

## ៣. វិស័យទេសចរណ៍មានភាពរីកចំរើនឿនលឿន

តំបន់ទេសចរណ៍ធម្មជាតិរបស់ខេត្តក្រចេះបានធ្វើឱ្យខេត្តនេះក្លាយទៅជាគោលដៅទេសចរណ៍ធម្មជាតិ ដ៏សំខាន់របស់ប្រទេសកម្ពុជា ។

ធនធានដំបូងក្នុងចំណោមភាពទាក់ទាញទាំងនេះគឺត្រីផ្សោតដ៏កម្រ ។ ថនិកសត្វទឹកសាបដែលរងការបំផ្លិចបំផ្លាញទាំងនេះ បានទាក់ទាញភ្ញៀវទេសចរណ៍ជាង ១១ 000 នាក់ ដែលចំណាយជាង ៣ លានដុល្លារ ឱ្យមកកាន់ខេត្តក្រចេះនេះជារៀងរាល់ឆ្នាំ ។

ដំណើររុករកតាមទន្លេមេគង្គ ដែលជាគម្រោងប្រឆាំងភាពក្រីក្រប្រកបដោយនិរន្តរភាព មានគោលបំណងបង្កើនចំនួនភ្ញៀវទេសចរណ៍មកកាន់តំបន់នេះឱ្យបានច្រើនសន្ធឹកសន្ធាប់ ។ ខេត្តក្រចេះ គឺជាចំណុចចាប់ផ្តើមសំរាប់ដំណើរកំសាន្តជាលក្ខណៈអេកូទេសចរណ៍ចម្ងាយ ២00គម រហូតទៅដល់ប្រទេសឡាវ ។ ការអភិវឌ្ឍន៍ដំណើរកំសាន្តនេះទទួលបានជំនួយឧបត្ថម្ភពីអង្គការ SNV និងអង្គការទេសចរណ៍ពិភពលោកនៃអង្គការសហប្រជាជាតិ ។ អង្គការបានទាញការសន្និដ្ឋានថា អាចនឹងមានភ្ញៀវទេសចរណ៍ចំនួន ២៥0 000 នាក់ មកទស្សនាខេត្តក្រចេះ ជាប្រចាំឆ្នាំក្នុងរយៈពេលដប់ឆ្នាំខាងមុខ ។

ការធ្វើដំណើរដោយទូកកាណូតតាមដងទន្លេមេគង្គមានចម្ងាយ ១៤0គម ដែលកាត់តាមខេត្តក្រចេះនេះផ្តល់នូវទិដ្ឋភាពថ្ងៃលិចដ៏គួរឱ្យទាក់ទាញ និងការទស្សនាទេសភាពដែលភាគខាងជើងឆ្ពោះទៅកាន់ខេត្តស្ទឹងត្រែង និងប៉ែកខាងត្បូងឆ្ពោះទៅកាន់ខេត្តកំពង់ចាម ។

នៅខេត្តនេះ ក៏មានតំបន់ព្រៃឈើធំៗមួយចំនួនផងដែរ ដូចជាភ្នំប្រាំពាន់ និងភ្នំព្រិច ដែលជាជម្រកសំរាប់សត្វព្រៃចម្រុះ ។ ភ្នំឥសីបតមៈ ផ្តល់នូវទិដ្ឋភាពដ៏ល្អក្រៃលែងនៅតាមផ្លូវទៅកាន់ប្រទេសឡាវ និងប្រទេសវៀតណាម ។

បន្ថែមពីលើតំបន់ទេសចរណ៍ធម្មជាតិទាំងនេះ ភូមិភាគនេះក៏ផ្តល់នូវបទពិសោធន៍វប្បធម៌ដ៏ល្អផងដែរ ។ នៅលើភ្នំ ភ្ញៀវទេសចរណ៍អាចដើរកំសាន្តមើលកុលសម្ព័ន្ធភ្នំជនជាតិភាគតិចបានយ៉ាងរីករាយ ។ មានកុលសម្ព័ន្ធចំនួន ៧ នៅក្នុងខេត្តក្រចេះនេះហើយមានកុលសម្ព័ន្ធ ៤ ផ្សេងទៀតនៅក្នុងបណ្តាខេត្តដែលជាប់គ្នានេះ ។ ភ្ញៀវទេសចរណ៍ អាចមើលឃើញពីលក្ខណៈនៃការរស់នៅតាមប្រពៃណី ព្រមទាំងការធ្វើសិប្បកម្មជាច្រើន ។

អតីតរាជធានី ឈ្មោះសម្ភុបុរៈ មានទីតាំងនៅក្នុងខេត្តនេះ ហើយផ្តល់ជាទីកន្លែងសំរាប់ការស្រាវជ្រាវស្ថាបត្យកម្មរចនាបទបារាំងចំណាស់ៗ ។ ខេត្តក្រចេះមានវត្តវិហារសសរមួយរយ ដែលបានកសាងឡើងនៅក្នុងសតវត្សទី១៦ ។ វត្តនេះមានប្រវត្តិទាក់ទងទៅនឹងរឿងព្រេងក្រពើនេនធន ។ ខេត្តក្រចេះ មានប្រាសាទផ្សេងៗជាច្រើន ដែលបានកសាងជាយូរមកហើយ គឺតាំងពីសតវត្សទី ៨ មកម្លេះ ។

ទំនៀមទំលាប់ និងប្រពៃណី ពិធីបុណ្យទាន និងបុណ្យបែបសាសនាផ្សេងៗ ព្រមទាំងសកម្មភាពជីវិតប្រចាំថ្ងៃគឺជាកញ្ចក់ឆ្លុះបញ្ចាំងពីកេរតំណែលវប្បធម៌របស់ខេត្តនេះ ។

*"ខេត្តក្រចេះមានសក្តានុពល ។ ប៉ុន្តែនៅតែត្រូវការវិនិយោគជាច្រើនថែមទៀត... មុននឹងខេត្តនេះក្លាយជាទីតាំងមួយគួរឱ្យកត់សំគាល់ ។ អ្វីដែលគួរឱ្យចូលចិត្តបំផុតរបស់ខេត្តនេះគឺសម្រស់ និងភាពរស់រាយរាក់ទាក់របស់ប្រជាពលរដ្ឋ និងអារម្មណ៍ដែលគិតថា អ្នកគឺជាកុលបុត្រខ្មែរមួយរូបយ៉ាងពិតប្រាកដ ។"*

- Luzi Matzig នាយកប្រតិបត្តិក្រុមដំណើរកំសាន្តអាស៊ី ។

## ៤. ការផ្គត់ផ្គង់អគ្គិសនីច្រើន

ខេត្តក្រចេះមានការផ្គត់ផ្គង់អគ្គិសនីពីប្រភពជាច្រើន រួមមានរោងចក្រពីទីរួមខេត្តក្រចេះ និងអ្នកផ្គត់ផ្គង់ថាមពលអគ្គិសនីឯកជននៅក្នុងស្រុកបួនផ្សេងទៀត ។

ក្រៅពីរោងចក្រអគ្គិសនីក្នុងមូលដ្ឋាន ស្រុកស្នួលរបស់ខេត្តក្រចេះនេះ ក៏ទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រទេសវៀតណាមផងដែរ ។

ការផ្គត់ផ្គង់ពីប្រភពថ្មីនឹងមានថែមទៀត ដោយសារយើងបានធ្វើការកសាងសមត្ថភាពគាំទ្រដល់មូលដ្ឋានកំណើនសេដ្ឋកិច្ចរបស់យើង ពោលគឺការងារនេះនឹងចាប់ផ្តើមក្នុងពេលឆាប់ៗនេះ ដោយមានបណ្តាញបញ្ជូនអគ្គិសនីពីខេត្តស្ទឹងត្រែងមកកាន់ខេត្តក្រចេះនេះ ។ ដោយការងារនេះត្រូវធ្វើរួចរាល់នៅឆ្នាំ ២0១0 ការសាងសង់នេះ នឹងបង្កើន និងកែលំអការផ្គត់ផ្គង់អគ្គិសនីរបស់ខេត្តក្រចេះនេះឱ្យកាន់តែប្រសើរឡើងថែមទៀត ។

បន្ថែមពីលើនេះទៀត មានគម្រោងបង្កើតស្ថានីយ៍ថាមពលវារីអគ្គិសនីសំបូរ ដែលមានសក្តានុពលមិនគួរឱ្យជឿ ។ ស្ថានីយ៍អាចនឹងមានសមត្ថភាពរហូតដល់ ៣៣00 មេហ្គាវ៉ាត់ ដែលអាចនឹងធ្វើឱ្យវាក្លាយទៅជាម៉ាស៊ីនភ្លើងដ៏ធំជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ ។ លើសពីនេះទៅទៀត ទីកដែលមានសក្តានុពលមាននៅទីតាំងតូចៗ ដូចជាព្រែកឆ្លូង ព្រែកទេ និងព្រែកជីមាន់ ។

## ៥. ធនធានធម្មជាតិដែលមិនទាន់បានទាញយកមកប្រើ

ជាមួយគ្នានឹងការផ្តោតលើការធានាឱ្យមាននូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ខេត្តក្រចេះក៏ផ្តល់នូវសក្តានុពលរ៉ែដ៏ច្រើនសន្ធឹកសន្ធាប់ផងដែរ ។ មានរ៉ែដ៏មានតម្លៃមួយចំនួននៅភូមិភាគនេះ រួមមានរ៉ែដែក ថ្មម៉ាប ត្បូងថ្ម សំណ ទង់ដែង ស្ពាន់ ស័ង្កសី ក្រានីត និងរ៉ែមាស ។

# ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត

ភូមិភាគនេះមានវិស័យកសិកម្មខ្លាំងក្លា និងរីកចំរើន ដែលផលិតនូវពោតក្រហម ល្ង ដំឡូងជ្វា អំពៅ សណ្តែកសៀង សណ្តែកបាយ ម្រេច អំពៅ និងស្វាយចន្ទី ។ សមាសភាពសំខាន់នៃទិន្នផលកសិកម្មរបស់យើងនាំចេញទៅប្រទេសវៀតណាម ។

ថ្នាំជក់គឺជាទិន្នផលចម្បងរបស់ខេត្តក្រចេះ បើតាមការគណនាគឺក្នុងរង្វង់ ១៨% នៃដំណាំរបស់កម្ពុជា ។ ក្រុមហ៊ុនចំរុះជាតិដែលនាំមុខគេរបស់កម្ពុជាឈ្មោះ British American Tobacco មានដំណើរការយ៉ាងសកម្ម ហើយធ្វើការយ៉ាងជិតស្និទ្ធជាមួយកសិករក្នុងមូលដ្ឋាន ដើម្បីធានានូវការដាក់បញ្ចូលស្លឹកថ្នាំជក់ដ៏សំខាន់នេះ ចូលទៅក្នុងសង្វាក់ផ្គត់ផ្គង់ជាលក្ខណៈអន្តរជាតិរបស់ខ្លួន ។ នៅខេត្តក្រចេះ ផ្ទៃដីសរុប ១១២0 ហិកតាជាផ្ទៃដីដាំដំណាំថ្នាំជក់ ។





ខេត្តក្រចេះ ក៏ជាខេត្តមួយដែលផលិតជ័រកៅស៊ូដ៏ច្រើនគួរឱ្យកត់សំគាល់ផងដែរ ដែលភាគច្រើននាំចេញទៅប្រទេសវៀតណាម ។ ក្រុមហ៊ុនចំនួន ដប់បី បានដាក់វិនិយោគផ្នែកដំណាំកៅស៊ូ ។ ក្រុមហ៊ុនផលិតមួយរបស់វៀតណាមមានគោលបំណងបង្កើនការប្រមូលផលជ័រកៅស៊ូរបស់ខ្លួននៅក្នុងខេត្តក្រចេះឆ្នាំនេះ ឱ្យបានច្រើនបំផុត គឺពី ២០០ ហិកតា រហូតដល់ ១៥០០ ហិកតា ។

ទិន្នផលដំឡូងមីក្នុងមូលដ្ឋានមានការរំពឹងថា នឹងមានការកើនឡើងទ្វេដងក្នុងឆ្នាំ ២០០៨-០៩ ។ ដោយមានទីតាំងនៅជិតប្រទេសវៀតណាម និងមានច្រកព្រំដែនអន្តរជាតិផងនោះ ភាគច្រើននៃដំណាំទាំងនេះ ត្រូវបាននាំចេញទៅលក់នៅប្រទេសវៀតណាមក្នុងតម្លៃជាសាកល ។

ផ្ទៃដីប្រហែល ២៥០ ហិកតា បានដាំសណ្តែកបាយ និង ២៣០០ ហិកតាទៀតដាំស្វាយចន្ទី ។

ក្រុមហ៊ុនចំនួនប្រាំ បានវិនិយោគនៅក្នុងការដាំដើមម៉ៃស័ក ហើយគេនឹងមានគម្រោងបង្កើតរោងអារឈើថ្មីមួយ ។

ក្រុមហ៊ុនកសិកម្មសរុបចំនួន ១៨ មានចុះបញ្ជីនៅខេត្តក្រចេះ:

| ក្រុមហ៊ុន | សកម្មភាព | ផ្ទៃដី(ហិកតា) |
|---|---|---|
| Green Island Ag.Devel. | ការកែច្នៃ និងការដាំដើមម៉ៃស័ក | 9,583 |
| Global Ag.Devel | ការកែច្នៃ និងការដាំដើមម៉ៃស័ក | 9,800 |
| Asia World Ag. Devel | ការកែច្នៃ និងការដាំដើមម៉ៃស័ក | 10,000 |
| Plantation Ag. Devel | ការកែច្នៃដើមក្លាលាន | 9,214 |
| Great Asset Ag. Devel | ការកែច្នៃដើមក្លាលាន | 8,985 |
| Great Wonder Ag. Devel | ការកែច្នៃដើមក្លាលាន | 9,231 |
| Phurieng Kratie Tieaphivatcaout Chouc | ដំណាំកៅស៊ូ | 915 |
| Heng Heng Sambath | ដំណាំកៅស៊ូ | 833 |
| Cambodia Tong Min Group | ដំណាំកៅស៊ូ និងដើមអាកាស្យា | 7,465 |
| Bravest Bridging Trading | ដំណាំកៅស៊ូ និងដើមអាកាស្យា | 8,525 |
| Phurieng Kratie Phivatcaout Chout | ដំណាំកៅស៊ូ | 6,525 |
| Cambodia Union Biotech | ដំណាំកៅស៊ូ ដើមអាកាស្យា និងដើមប្រេងខ្យល់ | 998 |
| Union Agricultural Development | ដំណាំកៅស៊ូ ដើមអាកាស្យា និងដើមប្រេងខ្យល់ | 997 |
| Dong Nai Kratie Aphivath | ដំណាំកៅស៊ូ | 2,502 |
| Dong Phu Kratie Aphivath | ដំណាំកៅស៊ូ | 2,349 |
| Dau Tu Saigon Binhphouc | ការកែច្នៃ និងដំណាំកៅស៊ូ | 6,436 |
| Civ Development Agro industry | ការកែច្នៃ និងដំណាំកៅស៊ូ និងដំឡូងមី | 769 |
| Hai Yong Agro-Industry Investment Co. | ការកែច្នៃ និងដំណាំកៅស៊ូ និងដំឡូងមី | 701 |

ក្រៅពីដំណាំ និងចំការរបស់យើង ខេត្តក្រចេះក៏មានឧស្សាហកម្មចិញ្ចឹមសត្វយ៉ាងសកម្មផងដែរ ដែលមានមាន់ទា ជ្រូក និងគោក្របីយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

ដោយមានតួនាទីសំខាន់នៅក្នុងសង្វាក់អាជីវកម្មរបស់កម្ពុជា យើងគឺជាអ្នកផ្គត់ផ្គង់ទំនិញនានា ដែលចាំបាច់សំរាប់ការលូតលាស់នៃឧស្សាហកម្មចិញ្ចឹមសត្វរបស់ខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគីរី ។ អាជីវកម្មរបស់យើងក៏ផលិតនូវម៉ាស៊ីនកិនស្រូវ និងម៉ាស៊ីនច្រូតស្រូវសំរាប់កសិកររបស់ខេត្តយើង និងបណ្តាខេត្តនានាដែលនៅជិតខេត្តយើងផងដែរ ។

ខេត្តក្រចេះ មានក្រុមហ៊ុនថ្មម៉ាបមួយចំនួន និងរោងចក្រថ្មម៉ាបមួយនៅក្នុងខេត្តកែច្នៃទិន្នផលបន្ថែមទៀត ។

ក្រៅពីកសិកម្ម ខេត្តក្រចេះក៏មានផលិតផលសិប្បកម្មសំរាប់ផ្គត់ផ្គង់ ដល់ទីផ្សារទេសចរណ៍ក្នុងមូលដ្ឋាន និងនាំចេញទៅបណ្តាខេត្តផ្សេងៗផងដែរ ។

ខេត្តក្រចេះមានក្រុមហ៊ុនឡឥដ្ឋ និងក្បឿងជាច្រើន ។ មានក្រុមហ៊ុន ចំនួន ១៥ នៅក្នុងស្រុកក្រចេះ ចំនួន ៦ នៅស្រុកព្រែកប្រសព្វ និង ៣ក្រុមហ៊ុន នៅស្រុកឆ្លូង ។

មានអាជីវកម្មធុនតូចជាច្រើន ដែលបើកដំណើរការនៅក្នុងខេត្តរបស់យើង ដោយក្នុងនោះមានអាជីវកម្មជាង ៣២០ ដែលបានចុះបញ្ជីរនៅមន្ទីរពាណិជ្ជកម្មរបស់ខេត្តយើង ។ ក្រៅពីនេះ ក៏មានសហគ្រាសខ្នាតតូចរាប់ពាន់ផងដែរ ។ សហគ្រាសទាំងនេះរួមមាន:

- ម៉ាស៊ីនកិនស្រូវ
- ផលិតគ្រឿងសង្ហារឹម
- សិប្បកម្ម
- ជួសជុលគ្រឿងយន្ត
- ផលិតអាហារ និងភេសជ្ជៈ
- លក់ដុំ និងរាយ
- សណ្ឋាគារ និងបដិសណ្ឋារកិច្ច
- សេវាផ្សេងៗទៀតជាច្រើន





## ឱកាសធ្វើអាជីវកម្ម

អាជ្ញាធរខេត្តក្រចេះគឺជាអ្នកគាំទ្រដែលយកចិត្តទុកដាក់ចំពោះអាជីវកម្មថ្មីៗ។ ជាឧទាហរណ៍: ដើម្បីជួយកសាងវិស័យកសិកម្មរបស់យើង យើងបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមហ៊ុនផលិតដំឡូងមី និងពោតលឿង។

យើងមើលឃើញនូវឱកាសដ៏ច្រើនក្រៃលែងសំរាប់ឱ្យអាជីវកម្មនានាមកទាញយកអត្ថប្រយោជន៍ពីសក្តានុពលភាព ដែលមានលក្ខណៈប្រកួតប្រជែងតាមរយៈការវិនិយោគថែមទៀតនៅក្នុងវិស័យ:

- **ជីករករ៉ែ** ដើម្បីទាញយកអត្ថប្រយោជន៍ធនធានធម្មជាតិដ៏ច្រើនរបស់យើង។ ចំនួនក្រុមហ៊ុនថ្មម៉ាបមួយចំនួនមានសកម្មភាពយ៉ាងសកម្មនៅក្នុងខេត្ត ហើយមានវិសាលភាពបន្ថែមទៀត ។ វិនិយោគិនដ៏មានសក្តានុពល បានកំពុងធ្វើការសិក្សាទៅលើស្រទាប់រ៉ែស័ង្កសី មាស និងដែក ។
- **វារីអគ្គិសនី** ទីតាំងដ៏មានសក្តានុពលរួមមាន ស្រុកសំបូរ កាំពី ព្រែកឆ្លូង ព្រែកទេ និងព្រែកជីមាន់ ។
- **កសិកម្ម** ខេត្តភាគច្រើនលើកកម្ពស់ផ្នែកដំណាំស្រូវ ពោត ដំឡូងមី បន្លែ ម្រេច ស្វាយចន្ទី និងដំណាំកៅស៊ូ ។ ហើយក៏មានឱកាសជាច្រើនផ្សេងទៀតផងដែរ នៅក្នុងការដាំដុះថ្នាំជក់ ។
- **ក្រុមហ៊ុនឡឥដ្ឋ និងក្បឿង**
- **ការដាំថ្នាំជក់**
- **កសិពាណិជ្ជកម្ម** ជាពិសេសកែច្នៃផលិតកម្មពោតលឿង បន្លែ និង ល្ងរបស់យើង ។ ទិន្នផលកសិកម្មមិនទាន់កែច្នៃរបស់យើងភាគច្រើននាំចេញទៅវៀតណាម ។
- **ទេសចរណ៍ធម្មជាតិ** ដោយមានចំនួនភ្ញៀវទេសចរណ៍ដែលរំពឹងថានឹងមានការកើនឡើងដប់ដងនៅឆ្នាំខាងមុខទៀតនោះ សេវាអេកូទេសចរណ៍ និងសេវាសណ្ឋាគារ និងបដិសណ្ឋារកិច្ច បានបង្ហាញនូវឱកាសវិនិយោគដ៏គួរឱ្យទាក់ទាញក្រៃលែង ។

## ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ

ទោះជាយើងមានមោទនភាពចំពោះសមិទ្ធិផលរបស់យើងក៏ដោយ ក៏យើងនៅតែបន្តពង្រឹង និងកែលំអនូវភាពទាក់ទាញផ្នែកវិនិយោគរបស់យើងថែមទៀតដែរ។ យើងនៅតែមានលក្ខណៈសកម្មនៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មរបស់យើង និងទាក់ទាញសហគ្រាសអាជីវកម្មនានាដែលនាំមុខគេ ឱ្យចូលមកកាន់ខេត្តរបស់យើង។ ការអភិវឌ្ឍន៍សំខាន់ៗមួយចំនួន ដែលកំពុងដំណើរការរួមមាន:

- យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មវិនិច្ឆ័យរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្រោមកម្មវិធីនេះ ផលិតផលនៅក្នុងខេត្តក្រចេះជាច្រើនទទួលបានការគាំទ្របន្ថែមទៀត ។ ផលិតផលដែលកំណត់អត្តសញ្ញាណដោយយុទ្ធសាស្ត្រនេះរួមមាន ស្វាយចន្ទី ដំឡូងមី សណ្តែកសៀង កៅស៊ូ សូត្រ និងសិប្បកម្មពីសូត្រ និងបសុសត្វ។ ជំនួយរួមមានការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និងការផ្សព្វផ្សាយពាណិជ្ជកម្ម កំណែទម្រង់ច្បាប់ និងការកសាងសមត្ថភាពគ្រប់គ្រង និងជំនាញក្នុងតំបន់ ។
- ដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងជួយជ្រោមជ្រែងក្នុងការអភិវឌ្ឍន៍ វិស័យឯកជននៅក្នុងខេត្តក្រចេះក្នុងឧស្សាហកម្មសំខាន់ៗ:

| គម្រោង | ដៃគូអភិវឌ្ឍន៍ | វិស័យ |
|---|---|---|
| ការអភិវឌ្ឍន៍ចំការកៅស៊ូគ្រួសារ | AFD | ដំណាំកៅស៊ូ |
| ការកែលំអគុណភាពកៅស៊ូកម្ពុជា និងបង្កើតលិខិតបញ្ជាក់អំពីគុណភាពបំណងដាក់លក់នៅលើទីផ្សារអន្តរជាតិ | AFD | ដំណាំកៅស៊ូ |
| គម្រោងពង្រីកកសិកម្មកម្ពុជា-អូស្ត្រាលី ដំណាក់កាលទី២ (CAAEP II) | AusAID | កសិកម្ម |
| គម្រោងទេសចរណ៍ | IFC | ទេសចរណ៍ |
| ដំណើរកំសាន្តរុករកតាមដងទន្លេមេគង្គ | SNV | ទេសចរណ៍ |
| ទេសចរណ៍VCA | SNV | ទេសចរណ៍ |
| គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម (MSME) | USAID | បសុសត្វ ត្រី ជ្រូក<br>ការកែច្នៃផលិតផលកសិកម្ម<br>ឡឥដ្ឋ-ក្បឿង |

## ត្រូវការស្វែងយល់បន្ថែមទៀតទេ?

សំរាប់ព័ត៌មានបន្ថែមស្តីអំពីឱកាសវិនិយោគ និងការអភិវឌ្ឍន៍នៅក្នុងខេត្តក្រចេះ សូមទាក់ទង:

**www.kratie.gov.kh**

**ឯកឧត្តម ខាំ ភឿន**
អភិបាលខេត្ត
+855 (0)12 923 937, (0)11 720 003

**ឯកឧត្តម ធុន ត្រី**
អភិបាលរងខេត្តក្រចេះ
+855 (0)12 459 205, (0)11 679 205

**ឯកឧត្តម ប្រាក់ សារុធ**
អភិបាលរងខេត្តក្រចេះ
+855 (0)12 625 032, (0)11 611 448

**លោក មិន ហុងស៊្រី**
នាយរងខុទ្ទកាល័យទីមួយ
+855 (0)11 905 215

**លោក ខាន់ ចំណាន**
នាយរងខុទ្ទកាល័យ
+855 (0)12 974 663

**លោក គុយ ហ៊្វត**
ប្រធានមន្ទីរកសិកម្មខេត្ត
Ph: +855 (0)72 971 408
M: +855 (0)12 855 470

**លោក លាង សេង**
អនុប្រធានមន្ទីរកសិកម្មខេត្ត
+855 (0)12 7297 1418

**លោក ម៉ៅ វិចិត្រ**
+855 (0)11 909 404

**www.cambodiainvestment.gov.kh**
**www.investincambodia.com**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - គណកម្មការវិនិយោគកម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៩៨១ ១៥៤
អ៊ីម៉ែល: CDC.CIB@online.com.kh
www.cambodianinvestment.gov.kh

វិទ្យាស្ថានជាតិស្ថិតិ:
www.nis.gov.kh

### ក្រសួងនានា

ក្រសួងពាណិជ្ជកម្ម
www.moc.gov.kh
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:
www.mef.gov.kh
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល:
www.mine.gov.kh
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
www.mlv.gov.kh
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់:
www.mlmupc.gov.kh
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍:
www.mptc.gov.kh
ក្រសួងសាធារណការណ៍ និងដឹកជញ្ជូន:
www.mpwt.gov.kh
ក្រសួងទេសចរណ៍:
www.mot.gov.kh
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ:
www.maff.gov.kh

### ផ្សេងៗ

សមាគមឧស្សាហកម្មកាត់ដេរនៅកម្ពុជា:
www.gmac-cambodia.org
វេទិកាវិស័យឯកជន-រដ្ឋាភិបាល:
www.cambodia-gpsf.org
សភាពាណិជ្ជកម្មភ្នំពេញ:
www.ppcc.org.kh
សមាគមឧស្សាហកម្មធុនតូច និងមធ្យមភ្នំពេញ
www.smecambodia.org

## ស្ថិតិ

| ស្ថានភាពទូទៅខេត្តក្រចេះ | |
|---|---|
| ចំនួនប្រជាជន: | 290,000 |
| អាយុពី 15-64: | 54.3% |
| សមាមាត្រការងារក្នុងវិស័យកសិកម្ម: | 70% |
| លំដាប់ថ្នាក់ភាពក្រីក្ររបស់ខេត្ត: | 14/24 |
| ផ្ទៃដី: | 11,094 km² |
| ដង់ស៊ីតេប្រជាជន:<br>(% ចំនួនប្រជាជនជាមធ្យម) | 33% |
| ចំនួនស្រុក: | 5 |
| ចំនួនឃុំ: | 46 |

## ស្ថានភាពដីក្នុងខេត្តក្រចេះ

ប្រភេទ: ដីប្រផេះអាស៊ីដខុសគ្នា ដីក្នុងតំបន់ជាំទឹកតាមស្រទាប់ ដីជាំទឹកពណ៌ប្រផេះ ដីពតសុលក្រហមលឿង ។ ហើយក៏មានដីល្បាប់ប្រផេះដែលនៅជិតទន្លេមេគង្គផងដែរ ។

កម្រិតជីវជាតិ: មធ្យម ប្រភព: www.cambodiaatlas.com

| អត្រាពន្ធនៅកម្ពុជា | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាប្រាក់លើកទឹកចិត្ត | 0% ឬ 9% |
| | | |
| ពន្ធអតិបរមា | | 1% ប្រាក់ចំណូល |
| ពន្ធកាត់ទុក | | 15% |
| ចំណូលបានមកពីការជួលអចលនទ្រព្យ | | 10% |
| ការទូទាត់ចំពោះមនុស្សចំណូលស្រុក | | 14% |
| ពន្ធលើប្រាក់ខែ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| 12,500,001 + | | 20% |
| មនុស្សចំណូលស្រុក | អត្រាថេរ | 20% |
| ពន្ធផលប្រយោជន៍បន្ទាប់បន្សំ | | 20% |
| តម្លៃបន្ថែមលើពន្ធ | | 10% |
| | នាំចេញ | 0% |
| ពន្ធផ្ទេរអចលនទ្រព្យ | | 4% |

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា | 2005 | 2006 | 2007 | 2008f | 2009f |
|---|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 7.5 | 7.0 |
| កំណើននាំចេញ (%) | 12.6 | 19.2 | 8.1 | 5.6 | 8.5 |
| នាំចេញ (% GDP) | 64.2 | 68.0 | 66.7 | 65.7 | 66.1 |
| FDI ($m) | 375 | 475 | 598 | 660 | 759 |
| FDI (% GDP) | 6.0 | 6.5 | 6.9 | 6.7 | 6.8 |

## ចំណាយអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| ភ្នំពេញ | $350-$2,000 |
| ដីធ្វើអាជីវកម្ម | $30-$100 |
| តំបន់ផ្សេង | $4-$30 |
| ជនបទ | $0.50-$5 |
| **ដីសំរាប់ការិយាល័យ** | **តម្លៃជួលក្នុងមួយខែ** |
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| ប្រាក់ជួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |
| ប្រាក់ជួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |

| តម្លៃអគ្គិសនីនៅភ្នំពេញ (excl. SEZs) | | |
|---|---|---|
| ឧស្សាហកម្ម | គីឡូវ៉ាត់ម៉ោង/ខែ | តម្លៃ (រៀល/គីឡូវ៉ាត់) |
| | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ការផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្ម | | $0.32/គ.ក្រ |

| តម្លៃពលកម្ម | ប្រាក់ខែ $ ក្នុងមួយខែ |
|---|---|
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | 1,000-1,500 |
| អ្នកគ្រប់គ្រងកណ្តាល | 500-1,000 |
| អ្នកគ្រប់គ្រងកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ជំនួយការ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាមទ្វារ | 50-80 |
| កម្មករ | 50-80 |
| ប្រាក់ឈ្នួលអប្បបរមារបស់កម្មករកាត់ដេរ | 60 |

# ខេត្តក្រចេះ

# សក្តានុពលវិនិយោគ



Photographs by Nathan Horton www.nathanhortonphotography.com

Designed by DESIGNGROUP www.dgcambodia.com